**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ

ក្រុមការងាររៀបចំប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩

**សូមគោរពជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា**

**កម្មវត្ថុ** សំណើសុំផ្សាយសេចក្តីជូនដំណឹង ស្តីពីការចែកប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ ជូនប្រជាពលរដ្ឋចំនួន ៦ខណ្ឌ រាជធានីភ្នំពេញ តាមរយៈទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្តិ៍លេខ៥ និង Fresh News ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក** ជ្រាបថា កន្លងមកក្រុមការងាររៀបចំប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ បានសហការជាមួយកងឯកភាពនៃកងយោធពលខេមរភូមិន្ទ ទទួលនិងចែកប័ណ្ណជូនប្រជាពលរដ្ឋដោយឥតបង់ប្រាក់ ក្នុងមូលដ្ឋានសង្កាត់ចំនួន៤៦ និងខណ្ឌចំនួន៦ រាជធានីភ្នំពេញ ។

ដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋមកទំនាក់ទំនងសាកសួរព័ត៌មាន ទទួលយកប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងមូលដ្ឋានសង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្រុមការងាររៀបចំប័ណ្ណ ស្នើសុំធ្វើការផ្សាយសេចក្តីជូនដំណឹងរបស់ក្រសួងការពារជាតិ ស្តីពីការចែកប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ កពជ ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានសង្កាត់ចំនួន៤៦ និងខណ្ឌចំនួន៦ រាជធានីភ្នំពេញ តាមរយៈទូរទស្សន៍កងយោធពលខេមរភូមិន្ទប៉ុស្តិ៍លេខ៥ ជារៀងរាល់ថ្ងៃនិងជួយរៀបចំរូបភាព (សកម្មភាពការងារចែកប័ណ្ណ) និង Fresh News ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក** ជួយសម្រួលដោយក្តីអនុគ្រោះ ។

សូម**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា** ទទួលនូវការគោរពអំពីខ្ញុំ ។

ថ្ងៃ អាទិត្យ ៣ រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២១

**ក្រុមការងាររៀបចំប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ កពជ**

**ប្រធាន**

នាយឧត្តមសេនីយ៍.មាស_សំអុល